ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ៥៥៦........សហវ.ប្រ.ក.

# ប្រកាស

## ស្តីពី

## ការណែនាំអនុវត្តអាករលើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់មិនជាប់អាករ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងណែនាំអនុវត្តអាករលើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់មិនជាប់អាករ ស្របតាមមាត្រា៥៧ នៃច្បាប់ស្ដីពីសារពើពន្ធ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧។

**ប្រការ ២.- គោលដៅ**

ប្រកាសនេះ មានគោលដៅកំណត់ឱ្យបានច្បាស់លាស់នូវទំនិញឬសេវាមួយចំនួន ដែលជាកម្មវត្ថុនៃការផ្គត់ផ្គង់មិនជាប់អាករ ដូចមានចែងក្នុងមាត្រា៥៧ នៃច្បាប់ស្ដីពីសារពើពន្ធ សំដៅធានាបាននូវសង្គតិភាពក្នុងការអនុវត្តអាករលើតម្លៃបន្ថែម ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច និងកាត់បន្ថយបន្ទុកចំណាយរបស់ប្រជាពលរដ្ឋលើការប្រើប្រាស់ទំនិញឬសេវាចាំបាច់មួយចំនួន ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

**ប្រការ ៣.- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលធ្វើការផ្គត់ផ្គង់មិនជាប់អាករ។

**ប្រការ ៤.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ÷

១- ពាក្យ "អាករ" សំដៅដល់ អាករលើតម្លៃបន្ថែម។

២- ពាក្យ "សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ" សំដៅដល់ សេវាខាងហិរញ្ញវត្ថុដែលទាញយកកម្រៃតប្រាក់លម្អៀងជាប្រាក់ចំណេញ ជាអាទិ៍មាន÷

- ក- ប្រតិបត្តិការទទួលប្រាក់បញ្ញើ ផ្ដល់ឥណទានឬឱ្យខ្ចីបុល ប៉ុន្តែមិនរួមបញ្ចូលកម្រៃសេវាដែលទាក់ទិននឹងការផ្ដល់ឥណទានឬខ្ចីបុល
- ខ- ការបោះផ្សាយលក់មូលបត្រក្នុងទីផ្សារដំបូង ការជួញដូរមូលបត្រឬឧបករណ៍ហិរញ្ញវត្ថុដទៃទៀត និងសេវាជាត់ទាត់និងទូទាត់ក្នុងទីផ្សារមូលបត្រកម្ពុជា
- គ- សេវាប្ដូរប្រាក់
- ឃ- សេវាប្រាតិភោគ
- ង- ការជួញដូរមាសដែលមិនទាន់កែច្នៃជាគ្រឿងអលង្ការ។

៣- ពាក្យ "ថាមពលអគ្គិសនី" សំដៅដល់ ថាមពលអគ្គិសនី ដែលត្រូវបានផ្គត់ផ្គង់សម្រាប់ការប្រើប្រាស់ក្នុងជីវភាពរស់នៅឬការប្រកបអាជីវកម្ម។ ការផ្គត់ផ្គង់ថាមពលអគ្គិសនីមិនរាប់បញ្ចូលទៅនូវការតបណ្ដាញនិងឧបករណ៍វាស់ស្ទង់នានា។

៤- ពាក្យ "ទឹកស្អាត" សំដៅដល់ ទឹកស្អាត ដែលត្រូវបានផ្គត់ផ្គង់សម្រាប់ការប្រើប្រាស់ក្នុងជីវភាពរស់នៅឬការប្រកបអាជីវកម្ម វៀរលែងតែទឹកផលិតសម្រាប់ទទួលទានគ្រប់ប្រភេទ។ ការផ្គត់ផ្គង់ទឹកស្អាតមិនរាប់បញ្ចូលទេនូវការដាក់បំពង់បង្ហូរនិងឧបករណ៍វាស់ស្ទង់នានា។

៥- ពាក្យ "ផលិតផលកសិកម្មមិនទាន់កែច្នៃ" សំដៅដល់ ដើម សំបក ស្លឹក ផ្កា ផ្លែ គ្រាប់ ឫស មើម ឬជំរ នៃរុក្ខជាតិដែលបានមកពីការធ្វើកសិកម្មដាំដុះក្នុងស្រុក ទោះត្រូវបានឬមិនទាន់បានហាន់ឬកិនបំបែកក្តី និងដែលមិនទាន់ត្រូវបានយកទៅកែច្នៃជាផលិតផលសម្រេច។

៦- ពាក្យ "កាកសំណល់រឹង-រាវ" សំដៅដល់ វត្ថុឬសារធាតុរឹង-រាវ ដែលលែងមានប្រយោជន៍ឬត្រូវបានឈប់ប្រើប្រាស់ឬតម្រូវឱ្យបោះបង់ចោល។

**ប្រការ ៥.- ការផ្គត់ផ្គង់ទំនិញឬសេវាដែលជាការផ្គត់ផ្គង់មិនជាប់អាករ**

ការផ្គត់ផ្គង់ទំនិញឬសេវាដូចខាងក្រោម គឺជាការផ្គត់ផ្គង់មិនជាប់អាករ÷

១- សេវាប្រៃសណីយ៍សាធារណៈ។

២- សេវារបស់មន្ទីរពេទ្យនិងគ្លីនិក សេវាខាងវេជ្ជសាស្ត្រនិងទន្តសាស្ត្រ និងការលក់ទំនិញបន្ទាប់បន្សំខាងវេជ្ជសាស្ត្រនិងទន្តសាស្ត្រដែលទាក់ទិននឹងការបំពេញសេវាទាំងនេះ។

៣- សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដែលជាកម្មសិទ្ធិទាំងស្រុងរបស់រដ្ឋ។

៤- សេវាធានារ៉ាប់រង។

៥- សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ។

៦- ការនាំចូលសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនដែលរួចពន្ធគយស្របតាមបទប្បញ្ញត្តិស្តីពីគយ។

៧- សកម្មភាពមិនស្វែងរកចំណេញដើម្បីបំរើផលប្រយោជន៍សាធារណៈ។

៨- សេវាសិក្សាអប់រំ។

៩- ថាមពលអគ្គិសនី និងទឹកស្អាត។

១០- ផលិតផលកសិកម្មមិនទាន់កែច្នៃ។

១១- សេវាប្រមូល ឬសម្អាតកាកសំណល់រឹង-រាវ។

**ប្រការ ៦.- ឥណទានអាករលើធាតុចូល**

ឥណទានអាករលើធាតុចូលលើការនាំចូល ឬការទិញក្នុងស្រុក នូវសម្ភារៈនិងវត្ថុធាតុដើមសម្រាប់ផលិតនិងផ្គត់ផ្គង់ទំនិញឬសេវា ដូចមានចែងក្នុងប្រការ៥ នៃប្រកាសនេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា២៩ ដល់មាត្រា៤១ នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម។

**ប្រការ ៧.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ